**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៧៣០០...សហវ.......

ថ្ងៃ ចន្ទ ៧កើត ខែចេត្រ ឆ្នាំកុរ ពស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០

**ជម្រាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា**

**កម្មវត្ថុ** : ករណីផ្អាកការនាំចេញស្រូវ និងអង្ករស ជាបណ្តោះអាសន្ន ។
**យោង** : អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅក្នុងសន្និសីទសារព័ត៌មាន នាថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា គោរពតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅក្នុងសន្និសីទសារព័ត៌មាន នាថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ដើម្បីធានាបាននូវចីរភាពនៃការផ្គត់ផ្គង់អង្ករនៅក្នុងប្រទេស ក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមណែនាំដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ចាត់វិធានការតាមនីតិវិធីជាធរមាន ផ្អាកការនាំចេញស្រូវ និងអង្ករស ចាប់ពីថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០២០ ជាបណ្តោះអាសន្ន រហូតដល់មានការជូនដំណឹងជាថ្មី ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមចាត់ចែងអនុវត្ត ប្រកបដោយប្រសិទ្ធភាព តាមការគួរ ។

សូមឯកឧត្តមទទួលការរាប់អានពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

***ចម្លងជូន÷***
*-ក្រសួងពាណិជ្ជកម្ម*
*-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*
*-សហព័ន្ធស្រូវ អង្ករ កម្ពុជា*
*-ឯកសារ-កាលប្បវត្តិ*